# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ......៤៤៥......ប្រ.ក...កសក

# ប្រកាស

## ស្ដីពី

## គោលការណ៍ណែនាំសម្រាប់សំណាកដីកសិកម្ម

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្ដីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១២/០០៥ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១០៥ អនក្រ.បក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៥ ស្ដីពីការបន្ថែមមុខងារភារកិច្ចឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផែនការនិងស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងមជ្ឈមណ្ឌលព័ត៌មាននិងឯកសារកសិកម្ម ចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្ដីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល ឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រនិងកែលម្អដីកសិកម្មឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូ ទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ



អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
N° 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh. Cambodia
ទូរស័ព្ទលេខ : (០២៣) ៧២៦ ១២៨/ ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone: (023) 726 128 / 726 129, Fax : (855) 23 - 217 320

- បានឃើញអនុក្រឹត្យលេខ២២៤ អនក្រ.បក ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៦ ស្ដីពីការដំឡើងនាយកដ្ឋានផលិតកម្មនិងបសុព្យាបាល ទៅជាអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ
- បានឃើញអនុក្រឹត្យលេខ៨១ អនក្រ.បក ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩ ស្ដីពីការកែសម្រួលមាត្រា២ មាត្រា២៥ មាត្រា២៦ និងមាត្រា៣៩នៃអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៨ និងមាត្រា២៧ថ្មី នៃអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៧
- បានឃើញប្រកាសលេខ៤១៥ ប្រក.កសក ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១២ ស្ដីពីនីតិវិធីនិងការតម្រូវបមាណីយសម្រាប់ការចុះបញ្ជីជីកសិកម្ម
- បានឃើញប្រកាសលេខ១៧៦ ប្រក.កសក ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៣ ស្ដីពីនីតិវិធីនៃការធ្វើអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្ម
- បានឃើញប្រកាសលេខ០៩៩ ប្រក.កសក ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៥ ស្ដីពីនីតិវិធីនៃការត្រួតពិនិត្យដើមគ្រា និងការផ្ដល់សុពលភាពផ្គត់ផ្គង់ចែកចាយថ្នាំកសិកម្មនិងជីកសិកម្ម
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-**

ប្រកាសនេះ មានគោលបំណងកំណត់គោលការណ៍ណែនាំអនុវត្តវិធានបច្ចេកទេសក្នុងការទទួលយក ឬដកយកសំណាកជីកសិកម្មគ្រប់ប្រភេទ។

**ប្រការ ២.-**

ប្រកាសនេះ មានគោលដៅបំពេញតាមលក្ខខណ្ឌពាក់ព័ន្ធនឹងសំណាកជីកសិកម្មដែលជាការតម្រូវដោយនីតិវិធីនៃច្បាប់ស្ដីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

**ប្រការ ៣.-**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះសំណាកជីកសិកម្មដូចខាងក្រោម៖

១-ការទទួលយកសំណាកបឋមសម្រាប់ឆ្លងកាត់ការវិភាគក្នុងដំណើរការអនុវត្តនីតិវិធី និងការតម្រូវបមាណីយសម្រាប់ការចុះបញ្ជីជីកសិកម្ម។

២-ការដកយកសំណាកផលិតផលជីកសិកម្ម ដើម្បីធ្វើការវិភាគផ្ទៀងផ្ទាត់បមាណីយធានានៃសារធាតុចិញ្ចឹម និងសារធាតុផ្សេងទៀត ក្នុងដំណើរការអនុវត្តនីតិវិធីនៃការត្រួតពិនិត្យដើមគ្រានិងការផ្ដល់សុពលភាពផ្គត់ផ្គង់ចែកចាយជីកសិកម្ម។

៣-ការដកយកសំណាកផលិតផលជីកសិកម្ម ដែលជាកម្មវត្ថុនៃការត្រួតពិនិត្យ និងការធ្វើវិភាគផ្ទៀងផ្ទាត់បមាណីយធានានៃសារធាតុចិញ្ចឹម និងសារធាតុផ្សេងទៀត នៅក្នុងដំណើរការអនុវត្តនីតិវិធីនៃការធ្វើអធិការកិច្ចជីកសិកម្ម។

**ប្រការ ៤.-**

វាក្យសព្ទដែលប្រើនៅក្នុងប្រកាសនេះ ត្រូវបានកំណត់ជានិយមន័យដូចខាងក្រោម ៖

១-**វិធានបច្ចេកទេស** សំដៅដល់បទប្បញ្ញត្តិស្តីពីបច្ចេកទេសដែលមានលក្ខណៈបញ្ជាឱ្យគោរពតាម ដើម្បីធានាឱ្យមានភាពច្បាស់លាស់ក្នុងការទទួលយក ឬដកយកសំណាកជីកសិកម្មក្នុងពេលអនុវត្តតាមនីតិវិធីនៃច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម។

២-**សំណាកជីកសិកម្ម** សំដៅដល់គំរូសំណាករបស់ជីកសិកម្ម ដែលត្រូវបែងចែកជា សំណាកបឋម ឬសំណាកធានា ឬសំណាកផលិតផលជីកសិកម្ម។

៣-**សំណាកបឋម** សំដៅដល់សំណាកជីកសិកម្មតាមយថាប្រភេទដែលជាកម្មវត្ថុសម្រាប់ការធ្វើវិភាគតាមពាក្យស្នើសុំចុះបញ្ជី។

៤-**សំណាកធានា** សំដៅដល់សំណាកជីកសិកម្មដែលបានប្រគល់ឱ្យរក្សាទុកនៅគ្រឹះស្ថាន ឬឃ្លាំងសន្និធិរបស់អ្នកស្នើសុំចុះបញ្ជីជីកសិកម្ម ក្រោយពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានយល់ព្រមលើការចុះបញ្ជី។

៥-**សំណាកផលិតផលជីកសិកម្ម** សំដៅដល់សំណាកជីកសិកម្មដែលត្រូវដកយកពីការត្រួតពិនិត្យដីមគ្រានិងដកយកមកពីការធ្វើអធិការកិច្ចជីកសិកម្ម។

៦-**កញ្ចប់សំណាក** សំដៅដល់សំបកវេចខ្ចប់សម្រាប់វេចខ្ចប់សំណាកជីកសិកម្មដែលបានទទួលយក ឬដកយក រួមមាន កញ្ចប់ កំប៉ុង ឬដប។

៧-**លេខរៀងឡូតិ៍** សំដៅដល់លេខអត្តសញ្ញាណនៃផលិតផលជីកសិកម្មដែលកំណត់ដោយរោងចក្រប្រភពដើម ឬការលាយផ្សំ ឬការវេចខ្ចប់ជាថ្មី។ ផលិតផលជីកសិកម្ម១ការុង ឬ១កញ្ចប់ ឬ១ដប ត្រូវសម្គាល់ដោយលេខរៀងឡូតិ៍ខុសៗគ្នាតាមលំដាប់លំដោយនៃខ្សែច្រវាក់ផលិតកម្ម។

៨-**ការបោះឬបិទត្រា** សំដៅដល់ការបោះឬបិទត្រាធ្វើជាស្លាកសញ្ញាសម្គាល់នៅលើកញ្ចប់សំណាកជីកសិកម្ម ឬលើសំបកវេចខ្ចប់ផលិតផលជីកសិកម្ម។

៩-**ទីតាំងធានា** សំដៅដល់ទីតាំងដែលអាចប្រមូលផ្តុំសំណាកផលិតផលជីកសិកម្ម។ ទីតាំងនេះ ត្រូវបានដាក់បញ្ជាឱ្យរក្សាបាននូវសុវត្ថិភាព និងហាមមិនឱ្យរើសំណាកចេញបានឡើយ លើកលែងតែមានការអនុញ្ញាតពីមន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្ម ឬមានគ្រោះអាសន្នកើតមានឡើង។

១០-**មន្ត្រីទទួលបន្ទុកការចុះបញ្ជី** សំដៅដល់មន្ត្រីដែលមានភារកិច្ចទទួលបន្ទុកការងារអនុវត្តការតម្រូវបមាណីយសម្រាប់ការចុះបញ្ជីជីកសិកម្មរបស់ នាយកដ្ឋាននីតិកម្មកសិកម្ម។

១១-**មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្ម** សំដៅដល់មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្មនៃនាយកដ្ឋាននីតិកម្មកសិកម្ម និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត ដែលបានចាត់តាំងឱ្យចុះបំពេញបេសកកម្មអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម។

## ជំពូកទី២
## សមត្ថកិច្ចអនុវត្ត

**ប្រការ ៥.-**

ការអនុវត្តគោលការណ៍សម្រាប់សំណាកជីកសិកម្ម ជាសមត្ថកិច្ចរបស់មន្ត្រីទទួលបន្ទុកការចុះបញ្ជី និងមន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

គ្រប់សំណាកជីកសិកម្មដែលទទួលយក ឬដកយក ត្រូវបញ្ជូនទៅវិភាគនៅមន្ទីរពិសោធន៍ជាតិកសិកម្ម ឬមន្ទីរពិសោធន៍ផ្សេងទៀតដែលមានការទទួលស្គាល់តាមបញ្ញត្តិមាត្រា៨៧នៃច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម។

**ប្រការ ៦.-**

សមត្ថកិច្ចទទួលយកសំណាកបឋម ឬដកយកសំណាកផលិតផលជីកសិកម្ម និងកាតព្វកិច្ចរក្សាទុកសំណាកធានា ត្រូវបានកំណត់ដូចខាងក្រោម៖

១-ការទទួលយកសំណាកបឋម ដើម្បីបញ្ជូនទៅធ្វើការវិភាគមុនពេលយល់ព្រមលើការចុះបញ្ជី ត្រូវអនុវត្តដោយមន្ត្រីទទួលបន្ទុកចុះបញ្ជីជីកសិកម្មនៃនាយកដ្ឋាននីតិកម្មកសិកម្ម។

២-ការទទួលរក្សាទុកសំណាកធានា ក្រោយពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ យល់ព្រមលើការចុះបញ្ជី ជាកាតព្វកិច្ចរបស់សាមីអ្នកស្នើសុំចុះបញ្ជីជីកសិកម្ម។

៣-ការដកយកសំណាកផលិតផលជីកសិកម្ម ដើម្បីបញ្ជូនទៅធ្វើការវិភាគផ្ទៀងផ្ទាត់បរិមាណីយធាតុនៃសារធាតុចិញ្ចឹម និងសារធាតុផ្សេងទៀតក្នុងពេលអនុវត្តនីតិវិធីត្រួតពិនិត្យដើមគ្រា ជាសមត្ថកិច្ចរបស់មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្មនៃនាយកដ្ឋាននីតិកម្មកសិកម្ម។

៤-ការដកយកសំណាកផលិតផល ដែលជាកម្មវត្ថុនៃការត្រួតពិនិត្យ និងការធ្វើវិភាគផ្ទៀងផ្ទាត់បរិមាណីយធាតុនៃសារធាតុចិញ្ចឹម និងសារធាតុផ្សេងទៀត ក្នុងពេលអនុវត្តនីតិវិធីនៃការធ្វើអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្ម ជាសមត្ថកិច្ចរបស់មន្ត្រីអធិការកិច្ចថ្នាំកសិកម្ម និងជីកសិកម្មនៃនាយកដ្ឋាននីតិកម្មកសិកម្ម។ ការដកយកសំណាកផលិតផលជីកសិកម្មនៅគ្រឹះស្ថានលក់ដុំលក់រាយ ដោយមន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្មនៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្តសាមី ត្រូវសហការជាមួយមន្ត្រីអធិការកិច្ចថ្នាំកសិកម្ម និងជីកសិកម្មនៃនាយកដ្ឋាននីតិកម្មកសិកម្ម។

## ជំពូកទី៣
## គោលការណ៍ណែនាំវិធានបច្ចេកទេសសម្រាប់សំណាកជីកសិកម្ម

**ប្រការ ៧.-**

ការអនុវត្តគោលការណ៍ណែនាំវិធានបច្ចេកទេសសម្រាប់សំណាកជីកសិកម្ម ត្រូវអនុវត្តតាមវិធានបច្ចេកទេសដាច់ដោយឡែកពីគ្នា ដូចខាងក្រោម៖

១-វិធានបច្ចេកទេសសម្រាប់សំណាកបឋម ដូចមានកំណត់ក្នុងប្រការ៨ នៃប្រកាសនេះ។

២-វិធានបច្ចេកទេសសម្រាប់សំណាកធានា ដូចមានកំណត់ក្នុងប្រការ៩ នៃប្រកាសនេះ។

៣-វិធានបច្ចេកទេសសម្រាប់សំណាកផលិតផលជីកសិកម្ម ដូចមានកំណត់ក្នុងប្រការ១០ នៃប្រកាសនេះ។

គ្រប់ការអនុវត្តវិធានបច្ចេកទេសសម្រាប់សំណាកជីកសិកម្មដូចបានកំណត់ក្នុងកថាខណ្ឌខាងលើ ត្រូវធ្វើអត្តសញ្ញាណជាចាំបាច់ដោយការបោះ ឬបិទត្រាសម្គាល់លើការទទួលយក ឬការដកយកសំណាកទាំងនោះ។

គំរូត្រា គំរូក្រដាសសុវត្ថិភាព និងការណែនាំធ្វើអត្តសញ្ញាណលើសំណាកជីកសិកម្ម ត្រូវបានកំណត់នៅក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ ៨.-**

ការទទួលយកសំណាកបឋម ត្រូវអនុវត្តតាមវិធានបច្ចេកទេសដូចខាងក្រោម៖

- មន្ត្រីទទួលបន្ទុកការចុះបញ្ជីជីកសិកម្ម ត្រូវពិនិត្យនិងកំណត់បរិមាណនៃសំណាកឱ្យសមស្រប និងវិធីសាស្ត្រវិភាគតាមទិន្នន័យយថាប្រភេទជីកសិកម្មនិងបរិមាណីយធាតុនៃសារធាតុចញ្ចឹម និងទិន្នន័យជីវប្រសិទ្ធភាព ដោយតម្រូវឱ្យសាមីអ្នកស្នើសុំចុះបញ្ជី ត្រូវធ្វើការវេចខ្ចប់បែងចែកជា៣(បី)សំណាក ក្នុង១យថាប្រភេទ ជីកសិកម្ម

- អ្នកស្នើសុំចុះបញ្ជី ត្រូវវេចខ្ចប់សំណាកទាំង៣នេះឱ្យបានល្អ ដោយសំណាកផលិតផលជីកសិកម្មប្រភេទជីគោក ត្រូវប្រើថង់ប្លាស្ទិកសម្រាប់វេចខ្ចប់ រីឯសំណាកផលិតផលជីកសិកម្មប្រភេទជីទឹក ត្រូវវេចខ្ចប់ដោយប្រើដបឬកំប៉ុងប្លាស្ទិក

- មន្ត្រីទទួលបន្ទុកការចុះបញ្ជីជីកសិកម្ម ត្រូវធ្វើអត្តសញ្ញាណដោយការបោះឬបិទត្រា និងបិទក្រដាសសុវត្ថិភាពសម្គាល់លើសំណាកទាំង៣(បី)នេះ ដើម្បីកំណត់អត្តសញ្ញាណឱ្យមានភាពច្បាស់លាស់មុនពេលប្រគល់ឱ្យសាមីអ្នកស្នើសុំចុះបញ្ជី បញ្ជូនទៅធ្វើការវិភាគ និងរក្សាទុកសំណាកធានា

- អ្នកស្នើសុំចុះបញ្ជី ទទួលខុសត្រូវក្នុងការប្រគល់សំណាកបឋមចំនួន៣(បី)សំណាកគឺ ១(មួយ)សំណាកបញ្ជូនទៅនាយកដ្ឋាននីតិកម្មកសិកម្ម ១(មួយ)សំណាក បញ្ជូនទៅឱ្យអង្គភាពទទួលបន្ទុកវិភាគសំណាកជីកសិកម្ម និង១(មួយ)សំណាកទៀត រក្សាទុកបណ្ដោះអាសន្ននៅគ្រឹះស្ថានរបស់ខ្លួន ដោយត្រូវរក្សាដល់គុណភាពសំណាកជីកសិកម្មទៅតាមលក្ខខណ្ឌបច្ចេកទេស

- អង្គភាពទទួលបន្ទុកការងារវិភាគ ត្រូវយកសំណាកទី១សម្រាប់ធ្វើការវិភាគផ្ទៀងផ្ទាត់រកសារធាតុចិញ្ចឹមចម្បងនិងបមាណីយធានា ឬធ្វើការសាកល្បងជីវប្រសិទ្ធភាពប្រសិនបើមានការតម្រូវឱ្យអនុវត្តតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា៥៦នៃច្បាប់ស្ដីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម រីឯសំណាកទី២សម្រាប់ផ្ទៀងផ្ទាត់រកសមាសធាតុបន្ទាប់បន្សំ និងមីក្រូសារធាតុ ឬសារធាតុបំប៉នផ្សេងទៀត។

**ប្រការ ៩.–**

ក្រោយពីទទួលបានវិញ្ញាបនបត្របញ្ជាក់បញ្ជិកាជីកសិកម្មដែលចេញដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សំណាកទី៣ដែលបានរក្សាទុកនៅគ្រឹះស្ថានរបស់សាមីអ្នកស្នើសុំចុះបញ្ជី ត្រូវចាត់ទុកសំណាកនោះជាសំណាកធានាជាស្ថាពរ។

ការទទួលរក្សាទុកសំណាកធានា អ្នកកាន់កាប់វិញ្ញាបនបត្របញ្ជាក់បញ្ជិកាជីកសិកម្ម ត្រូវអនុវត្តតាមវិធានបច្ចេកទេសដូចខាងក្រោម៖

- ត្រូវបន្តរក្សាទុកសំណាកធានានៅគ្រឹះស្ថាន ឬនៅឃ្លាំងសន្និធិរបស់ខ្លួន ដើម្បីទុកសម្រាប់ធ្វើការវិភាគផ្ទៀងផ្ទាត់ឡើងវិញនៅពេលមានការតម្រូវតាមនីតិវិធីនៃការត្រួតពិនិត្យដើមគ្រាជាមួយផលិតផលជីកសិកម្មដែលបាននាំចូលនាំចេញ ឬការលាយផ្សំ ឬវេចខ្ចប់ជាថ្មី និងតាមនីតិវិធីនៃការធ្វើអធិការកិច្ចផលិតផលជីកសិកម្មដែលបានផ្គត់ផ្គង់ចែកចាយទូទាំងប្រទេស

- មិនត្រូវផ្ទេរសំណាកធានាចេញពីសំបកវេចខ្ចប់ ដែលបានធ្វើអត្តសញ្ញាណដោយមន្ត្រីទទួលបន្ទុកចុះបញ្ជីជីកសិកម្ម

- ត្រូវរក្សាទុកសំណាកធានាដាច់ដោយឡែកពីផលិតផលជីកសិកម្មដែលមាននៅក្នុងសន្និធិ រហូតដល់កាលបរិច្ឆេទផុតសុពលភាពបញ្ជិកា

- ត្រូវប្រគល់ត្រលប់មកវិញ ក្នុងករណីមានការតម្រូវដោយមន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្មយកមកធ្វើការវិភាគផ្ទៀងផ្ទាត់ជាមួយសំណាកផលិតផលជីកសិកម្ម

- ក្នុងករណីគ្មានការតម្រូវតាមនីតិវិធីនៃការធ្វើអធិការកិច្ចជីកសិកម្ម ដែលពាក់ព័ន្ធនឹងការដកយកសំណាកផលិតផលជីកសិកម្មមកធ្វើវិភាគផ្ទៀងផ្ទាត់សារធាតុឡើងវិញទេ នាយកដ្ឋាននីតិកម្មកសិកម្ម ត្រូវអនុញ្ញាតឱ្យម្ចាស់សំណាកធានា យកសំណាកធានាដែលបានរក្សាទុក ទៅប្រើប្រាស់ជាមួយដំណាំពាក់ព័ន្ធផ្សេងៗ មុនផុតកាលបរិច្ឆេទជាស្ថាពរនៃសុពលភាពប្រើប្រាស់។

**ប្រការ ១០.–**

ការដកយកសំណាកផលិតផលជីកសិកម្ម ត្រូវអនុវត្តតាមគោលការណ៍ចាប់យកតាមលេខរៀងឡូតិ៍។

ករណីផលិតផលជីកសិកម្មពុំមានលេខរៀងឡូតិ៍ មន្ត្រីជំនាញមានសមត្ថកិច្ច ត្រូវចាប់យកពីគំនរណាមួយដោយការគណនាចំនួនសរុបនៃផលិតផលជីកសិកម្មដែលមានក្នុងឃ្លាំងសន្និធិ ឬនៅទីតាំងលក់ដុំលក់រាយ។

ការដកយកសំណាកផលិតផលជីកសិកម្មតាមយថាប្រភេទ ដែលត្រូវអនុវត្តតាមគោលការណ៍ចាប់យកតាមលេខរៀងឡូតិ៍ មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្ម អាចអនុវត្តតាមវិធីចាប់យកដោយចៃដន្យពីលេខគំនរណាមួយ។

ការអនុវត្តវិធានបច្ចេកទេសក្នុងការដកយកសំណាកផលិតផលជីកសិកម្ម ត្រូវអនុវត្តដូចខាងក្រោម៖

- សំណាកផលិតផលជីកសិកម្មប្រភេទជីគោក ត្រូវប្រើកញ្ចប់សំណាកជាប្រភេទថង់ប្លាស្ទិកសម្រាប់វេចខ្ចប់ រីឯសំណាកផលិតផលជីកសិកម្មប្រភេទជីទឹក ត្រូវវេចខ្ចប់ដោយប្រើដបឬកំប៉ុងប្លាស្ទិក

- ផលិតផលជីកសិកម្មប្រភេទជីគោកមានទម្ងន់លើសពី២គីឡូក្រាម ត្រូវរំលែកចេញពីសំបកវេចខ្ចប់ដោយប្រើឧបករណ៍ដែលអាចចូកយកតាមផ្នែកខាងលើនៃសំបកវេចខ្ចប់ជីកសិកម្មដើម្បីរំលែកទៅកញ្ចប់សំណាកផលិតផលជីកសិកម្ម

- ផលិតផលជីកសិកម្មជាប្រភេទជីទឹកមានចំណុះលើសពី២លីត្រ ត្រូវរំលែក ឬចាក់បង្ហូរចេញពីសំបកវេចខ្ចប់ទៅកញ្ចប់សំណាកផលិតផលជីកសិកម្ម

- មិនត្រូវផ្ទេរ ឬរំលែកចេញពីសំបកវេចខ្ចប់ទៅកញ្ចប់សំណាកផលិតផលជីកសិកម្ម ប្រសិនបើផលិតផលជីកសិកម្មដែលត្រូវដកយកសំណាក មានទម្ងន់ត្រឹម២គីឡូក្រាមចុះ ឬមានចំណុះត្រឹម២លីត្រចុះ ដោយត្រូវចាត់ទុកជាសំណាកផលិតផលជីកសិកម្មជាស្វ័យប្រវត្តិ

- ត្រូវធ្វើអត្តសញ្ញាណទាំងលើផលិតផលជីកសិកម្មដែលត្រូវបានដកយកសំណាក និងសំណាកផលិតផលជីកសិកម្ម ដោយអនុវត្តការបោះឬបិទត្រាលើសំបកវេចខ្ចប់ផលិតផលជីកសិកម្ម កញ្ចប់សំណាក និងត្រូវបិទភ្ជិតឱ្យបានល្អនៅត្រង់កន្លែងដែលស្រាយ ឬមួលផ្ទេររំលែកសំណាក ព្រមទាំងមានបិទក្រដាសសុវត្ថិភាពឱ្យបានត្រឹមត្រូវ

- ត្រូវដកយកសំណាកផលិតផលជីកសិកម្មជា៤(បួន) សំណាក ដែលត្រូវរក្សាទុកនៅមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្តសាមីចំនួន១សំណាក បញ្ជូនមកនាយកដ្ឋាននីតិកម្មកសិកម្មចំនួន១សំណាក និងសម្រាប់ធ្វើការវិភាគនៅមន្ទីរពិសោធន៍ចំនួន១សំណាក រីឯ១សំណាកទៀត និងផលិតផលជីកសិកម្មដែលបានដកយកសំណាក ត្រូវរក្សាទុកបណ្តោះអាសន្ននៅទីតាំងធានាក្នុងឃ្លាំងសន្និធិ ឬគ្រឹះស្ថានលក់ដុំលក់រាយជីកសិកម្មដែលបានចុះត្រួតពិនិត្យដកយកសំណាកនោះ

- ការដកយកសំណាកផលិតផលជីកសិកម្មតាមយថាប្រភេទ មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្ម ត្រូវធ្វើកំណត់ហេតុដកយកសំណាកផលិតផលជីកសិកម្ម ដោយត្រូវធ្វើនៅទីតាំងដែលបានចុះត្រួតពិនិត្យ និងត្រូវដាក់កំណត់ហេតុដកយកសំណាកនេះ បញ្ចូលទៅក្នុងសំណុំឯកសារចុះត្រួតពិនិត្យ។

## ជំពូកទី៤
## ការធ្វើវិភាគផ្ទៀងផ្ទាត់ និងលក្ខណៈវិនិច្ឆ័យតាមលទ្ធផល

**ប្រការ ១១.-**

មន្ត្រីទទួលបន្ទុកការងារពិសោធន៍ ត្រូវធ្វើអត្តសញ្ញាណលើសំណាកជីកសិកម្មដែលបានបញ្ជូនមក ដោយត្រូវអនុវត្តតាមពិធីសារបច្ចេកទេសនៃដំណើរការពិសោធន៍សំណាកជីកសិកម្ម។

គ្រប់សំណាកជីកសិកម្មដែលបានធ្វើអត្តសញ្ញាណត្រឹមត្រូវរួចរាល់ ត្រូវធ្វើការវិភាគផ្ទៀតផ្ទាត់ដូចខាងក្រោម៖

១- អនុវត្តការវិភាគផ្ទៀងផ្ទាត់លើសំណាកជីកសិកម្មតាមការតម្រូវបមាណីយធានា រួមមាន រកកំហាប់នៃសារធាតុចិញ្ចឹមចម្បងរកកំហាប់នៃសមាសធាតុបន្ទាប់បន្សំ (លោហៈធ្ងន់) និងមីក្រូសារធាតុ។

២- ធ្វើការវិភាគផ្ទៀងផ្ទាត់បញ្ជាក់អំពីសុពលភាពប្រើប្រាស់របស់ផលិតផលជីកសិកម្ម។

៣-ធ្វើការវិភាគផ្ទៀងផ្ទាត់បញ្ជាក់អំពីគុណភាពរបស់ផលិតផលជីកសិកម្ម។

៤-ធ្វើការវិភាគស្រាវជ្រាវរកសារធាតុជំរុញការលូតលាស់របស់រុក្ខជាតិ ឬជំណាំលើសកម្រិតខុសប្រក្រតី ឬលាយផ្សំសារធាតុដែលគ្រោះថ្នាក់ និងហាមឃាត់ ។

ក្រោយពីបញ្ចប់ដំណើរការពិសោធន៍សំណាកជីកសិកម្ម អង្គភាពទទួលបន្ទុកការងារវិភាគផ្ទៀងផ្ទាត់សំណាកជីកសិកម្ម ត្រូវធ្វើការបរិយាយបញ្ជាក់លម្អិត និងច្បាស់លាស់អំពីលទ្ធផលវិភាគសំណាកជីកសិកម្មតាមយថាប្រភេទ។

**ប្រការ ១២.–**

ការទទួលបន្ទុកលើចំណាយការវិភាគសំណាកបឋមក្នុងការអនុវត្តនីតិវិធី និងការគម្រូវបមាណីយសម្រាប់ការចុះបញ្ជីជីកសិកម្ម ជាបន្ទុករបស់សាមីអ្នកស្នើសុំចុះបញ្ជីជីកសិកម្ម។

ក្រោយពីលទ្ធផលនៃការធ្វើវិភាគលើសំណាកផលិតផលជីកសិកម្ម បង្ហាញថា ពុំមានភាពអនុលោមតាមការគម្រូវបមាណីយដែលបានអះអាងក្នុងពេលចុះបញ្ជីជីកសិកម្ម ម្ចាស់ផលិតផលជីកសិកម្មដែលបានផ្គត់ផ្គង់ចែកចាយជីកសិកម្ម ត្រូវទទួលទោសបញ្ញត្តិដែលមានចែងក្នុងច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម និងត្រូវទទួលបន្ទុកលើចំណាយការធ្វើវិភាគសំណាក និងការចំណាយលើការលើកដាក់ ការដឹកជញ្ជូន ការថែរក្សា និងការបំផ្លាញចោលវត្ថុតាងដែលបានចាប់យកដោយមន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្ម លើកលែងតែលទ្ធផលបង្ហាញថា មានភាពអនុលោមការគម្រូវបមាណីយដែលបានអះអាងក្នុងពេលចុះបញ្ជីជីកសិកម្ម រាល់ការចំណាយលើការដកយកសំណាកផលិតផលជីកសិកម្មជាបន្ទុករបស់រដ្ឋ។

**ប្រការ ១៣.–**

លទ្ធផលវិភាគសំណាកបឋម ជាលក្ខណវិនិច្ឆ័យសម្រាប់ការយល់ព្រមលើការចុះបញ្ជីជីកសិកម្ម ឬបដិសេធលើការចុះបញ្ជីជីកសិកម្ម។

លទ្ធផលវិភាគសំណាកផលិតផលជីកសិកម្ម ដែលមានភាពវិជ្ជមានជាលក្ខណវិនិច្ឆ័យសម្រាប់មន្ត្រីអធិការកិច្ចថ្នាំកសិកម្ម និងជីកសិកម្មនៃនាយកដ្ឋាននីតិកម្មកសិកម្ម សម្រេចអនុញ្ញាតឱ្យម្ចាស់ផលិតផលជីកសិកម្មបន្តធ្វើប្រតិបត្តិការពាណិជ្ជកម្មជីកសិកម្ម។

លទ្ធផលវិភាគសំណាកផលិតផលជីកសិកម្ម ដែលមានភាពអវិជ្ជមានជាលក្ខណវិនិច្ឆ័យសម្រាប់មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្មនៃនាយកដ្ឋាននីតិកម្មកសិកម្ម ធ្វើការពិនិត្យផ្ទៀងផ្ទាត់ជាមួយនឹងទោសប្បញ្ញត្តិមានចែងក្នុងច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម តាមករណីណាមួយដូចខាងក្រោម៖

១-ផលិតផលជីកសិកម្មជាប្រភេទជីកសិកម្មក្រោមបមាណីយ ឬផុតសុពលភាពប្រើប្រាស់ដូចមានចែងក្នុងចំណុចទី៥ មាត្រា១០៧ នៃច្បាប់។

២-ផលិតផលជីកសិកម្មជាប្រភេទជីកសិកម្មដែលមានការក្លែងបន្លំសមាសធាតុ ឬមានសមាសធាតុផ្សេងពីការអះអាងនៅពេលស្នើសុំការចុះបញ្ជី ឬជាផលិតផលក្រៅបមាណីយ ឬក្លែងបន្លំប្រភពដើម ដូចមានចែងក្នុងចំណុចទី៤ និងចំណុចទី៥ មាត្រា១០៩ នៃច្បាប់។

៣-ផលិតផលជីកសិកម្មមានលាយសារធាតុជំរុញការលូតលាស់របស់រុក្ខជាតិ ឬជំណាំលើសកម្រិតខុសប្រក្រតី ឬលាយផ្សំសារធាតុដែលគ្រោះថ្នាក់ និងហាមឃាត់ ដូចមានចែងក្នុងចំណុចទី២ មាត្រា១១០ នៃច្បាប់។

៤-ផលិតផលជីកសិកម្មជាប្រភេទជីកសិកម្មខូចគុណភាពដែលអាចនាំឱ្យគ្រោះថ្នាក់សុខភាពមនុស្ស សត្វ និងបរិស្ថានដូចមានចែងក្នុងចំណុចទី៤ មាត្រា១១០ នៃច្បាប់។

## ជំពូកទី៥

## អន្តរប្បញ្ញត្តិ

**ប្រការ ១៤.-**

ការទទួលយក ឬដកយកសំណាកដីកសិកម្មគ្រប់ប្រភេទ ដែលបានកំណត់ដោយបទប្បញ្ញត្តិមុនៗពាក់ព័ន្ធនឹងការចុះបញ្ជីដីកសិកម្ម ការត្រួតពិនិត្យដើមគ្រា និងការធ្វើអធិការកិច្ចដីកសិកម្ម ត្រូវអនុវត្តបន្ថែមនូវគោលការណ៍បច្ចេកទេស និងលក្ខខណ្ឌដូចបានកំណត់ក្នុងបទប្បញ្ញត្តិនៃប្រកាសនេះ។

ការប្រើប្រាស់កំណត់ហេតុដកយកសំណាកផលិតផលដីកសិកម្ម ត្រូវយកតាមទម្រង់លេខ០៤ ដូចបានកំណត់ក្នុងសារាចរអន្តរក្រសួងលេខ៣២១ សរ.កសក ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីទម្រង់ឯកសារសម្រាប់នគរបាលយុត្តិធម៌នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រើប្រាស់ក្នុងការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម។

## ជំពូកទី៦

## អវសានប្បញ្ញត្តិ

**ប្រការ ១៥.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ១៦.-**

អគ្គលេខាធិការ អគ្គាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានកសិកម្ម ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ ប្រធានគ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទ និងប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១២កើត ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២០

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

**កន្លែងទទួល៖**
- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- -ក្រសួងយុត្តិធម៌
- -ក្រសួងមហាផ្ទៃ
- -ក្រសួងពាណិជ្ជកម្ម
- -ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- -ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- -ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- -រដ្ឋបាលរាជធានី ខេត្ត
- -ដូចប្រការ១៦
- -រាជកិច្ច
- -ឯកសារ កាលប្បវត្តិ